ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
គណៈកម្មាធិការលទ្ធកម្ម (គល-PC)
លេខៈ ០៤៧.......សជណ/គល/១៩

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## សេចក្ដីជូនដំណឹង
## ស្ដីពី
## ការអញ្ជើញចូលរួមដេញថ្លៃផ្គត់ផ្គង់ប្រេងឥន្ធនៈឆមាសទី២ ឆ្នាំ២០១៩ ជូនកងហោះដឹកជញ្ជូនប្រតិភូជាន់ខ្ពស់

ទីស្ដីការគណៈរដ្ឋមន្ត្រី សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ទីស្ដីការគណៈរដ្ឋមន្ត្រី នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់ប្រេងឥន្ធនៈឆមាសទី២ ឆ្នាំ២០១៩ ជូនកងហោះដឹកជញ្ជូនប្រតិភូជាន់ខ្ពស់។

ទីស្ដីការគណៈរដ្ឋមន្ត្រី បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មទីស្ដីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី ២០...... ខែ សីហា......ឆ្នាំ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០២៣ ២១២៤៧៩ )។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃនៅវេលាម៉ោង ៩ៈ០០ ថ្ងៃទី ២០......ខែ កញ្ញា........ឆ្នាំ២០១៩។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅសាលប្រជុំលេខ 1-16A វេលាម៉ោង ៩ៈ០០..... ថ្ងៃទី ២០...... ខែ កញ្ញា......ឆ្នាំ២០១៩ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃនិងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃអង្គារ ៥ រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៩
**ប្រធានគណៈកម្មាធិការលទ្ធកម្ម** (គល-PC)

ប្អូន លឹមហេង

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ